01009042

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារលេខ៖ D103/4

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ១២)

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន** **ប្រធាន**
**ចៅក្រម** Rowan DOWNING
**ចៅក្រម ន៉ីយ ថុល**
**ចៅក្រម** Chang-Ho CHUNG
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: **ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៤**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 20 / 08 / 2014
ម៉ោង (Time/Heure) : 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

---

[redacted] **សាធារណៈ: ( សំណៅកោសលុប )**

## សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបន្តបដិសេធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនដាក់សំណើសុំការពិចារណាទាំងឡាយរបស់ [redacted] ទៅក្នុងសំណុំរឿង និងការបន្តបដិសេធមិនចាត់ការលើសំណើទាំងនេះ

---

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីម្ចាស់បណ្តឹងឧទ្ធរណ៍:**

អាង ឧត្តម
Michael G. KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី:**

ហុង គឹមសួន
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Mahdev MOHAN
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. C.E.T.C.

**អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបន្តបដិសេធរបស់សហចៅក្រមស៊ើបអង្កេត មិនដាក់សំណើសុំការពិចារណាទាំងឡាយរបស់ [redacted] ទៅក្នុងសំណុំរឿង និងការបន្តបដិសេធមិនចាត់ការលើសំណើទាំងនេះ" ដែលបានដាក់នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៤ ("ម្ចាស់បណ្តឹងឧទ្ធរណ៍" និង"បណ្តឹងឧទ្ធរណ៍")[1]។

## I. សេចក្តីផ្តើម

1. បណ្តឹងឧទ្ធរណ៍ធ្វើឡើងប្រឆាំងការបន្តបដិសេធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនដាក់ចូលទៅក្នុងសំណុំរឿង នូវសំណើសុំការពិចារណាចំនួន ២០ ដែលដាក់ដោយសហមេធាវី ក្នុងនាមម្ចាស់បណ្តឹងឧទ្ធរណ៍ និងការបន្តបដិសេធមិនចាត់ការលើសំណើទាំងនេះ ដោយផ្អែកលើមូលដ្ឋានដែលថា នៅពេលនោះ សហមេធាវីមិនត្រូវបានទទួលស្គាល់ថាជាអ្នកតំណាងផ្លូវច្បាប់របស់ម្ចាស់បណ្តឹងឧទ្ធរណ៍។

### ក. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ ប្រធានអង្គភាពគាំពារការការពារក្តី បានជូនដំណឹងទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ថា ម្ចាស់បណ្តឹងឧទ្ធរណ៍បានជ្រើសរើស អាង ឧត្តម និង Michael G. KARNAVAS ជាសហមេធាវីរបស់គាត់[2]។ នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាអន្តរជាតិ បានជំទាស់ទៅនឹងការតែងតាំងសហមេធាវី ដោយផ្អែកលើមូលដ្ឋាននៃការចោទប្រកាន់ពីទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន[3]។

3. ក្នុងអំឡុងរវាងពីថ្ងៃទី ២៩ ខែ សីហា ដល់ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៣ សហមេធាវីបានដាក់សំណើចំនួន ដប់បួន ទៅ ក.ស.ច.ស[4]។ មានតែសំណើមួយគត់ ក្នុងចំណោមសំណើទាំងអស់នេះ

---

[1] ឯកសារ D103/1។

[2] លិខិតផ្ញើជូនសហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធការតែងតាំងសហមេធាវីការពារជនសង្ស័យក្នុងសំណុំរឿង ០០៣, ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ D56។

[3] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបដិសេធការតែងតាំងសហមេធាវីដែលត្រូវបានជ្រើសរើស ដោយផ្អែកលើមូលដ្ឋាននៃទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន, ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ D56/1។

[4] សំណុំរបស់ [redacted] ចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ, ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៣, ឯកសារ D82 និង D87/2/1.2។ សំណើរបស់ [redacted] សុំព័ត៌មានទាក់ទងវិធីសាស្ត្រ និងមធ្យោបាយស៊ើបអង្កេត

គឺសំណើសុំចូលពិនិត្យមើលសំណុំរឿង និងសុំចូលរួមក្នុងកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ ("សំណើសុំចូលពិនិត្យមើលសំណុំរឿង") ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង នៅពេលនោះ។ នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងដល់សហមេធាវីថា ដោយសារតែការជាប់ពាក់ព័ន្ធដែលអាចមាន ជាមួយការចោទប្រកាន់ពីទំនាស់ផលប្រយោជន៍ សំណើទាំងដប់បួន នឹងត្រូវដោះស្រាយនៅក្នុងពេលវេលាសមស្រប ដោយផ្អែកលើលទ្ធផលនៃការសម្រេចរបស់ ស.ច.ស.អ ទៅលើបញ្ហានេះ ("លិខិតរបស់ ក.ស.ច.ស ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣")[5]។ នៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣ សហមេធាវី បានប្ដឹងឧទ្ធរណ៍

---

របស់ ក.ស.ច.ស, ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៣,ឯកសារ D87/2/1.3។ សំណើរបស់ [redacted] សុំលទ្ធផលការងាររបស់អ្នកស៊ើបអង្កេត ក.ស.ច.ស ទាក់ទងការអនុវត្តកិច្ចស៊ើបសួរដែលមិនត្រឹមត្រូវ ក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D87/2/1.9។ សំណើរបស់ [redacted] សុំការស្រាយបំភ្លឺពាក់ព័ន្ធថាតើ មេធាវីការពារក្ដីអាចធ្វើការស៊ើបអង្កេតបានដែរឬទេ នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន, ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D87/2/1.12 ។ ការជូនដំណឹងរបស់ [redacted] ពីការជំទាស់មិនឲ្យលោក Steven Header ចូលរួមបន្ថែមទៀតនៅក្នុងសំណុំរឿង ០០៣ និងសំណើសុំលទ្ធផលស៊ើបអង្កេតរបស់លោក Steven Header,ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D87/2/1.4។ការជូនដំណឹងរបស់ [redacted] ពីការជំទាស់មិនឲ្យលោក David Boyle ចូលរួមបន្ថែមទៀតនៅក្នុងសំណុំរឿង ០០៣ និងសំណើសុំលទ្ធផលស៊ើបអង្កេតរបស់លោក David Boyle,ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D87/2/1.5។ សំណើរបស់ [redacted] សុំឲ្យផ្តល់ជូននូវលិខិតរបស់ប្រធានផ្នែកច្បាប់នៃ ក.ស.ច.ស ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ និងឯកសារពាក់ព័ន្ធទាំងអស់ ព្រមទាំងស្នើសុំឲ្យដាក់បញ្ចូលឯកសារទាំងនេះចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D87/2/1.6។ សំណើរបស់ [redacted] សុំការស្រាយបំភ្លឺថាតើ ក.ស.ច.ស ពិចារណាថាខ្លួនត្រូវបានចងកាតព្វកិច្ចដោយយុត្តិសាស្ត្ររបស់ អង្គជំនុំជម្រះដែលថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឲ្យមានទំនាក់ទំនងជាមួយជំលោះប្រដាប់អាវុធដែរឬយ៉ាងណា, ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D87/2/1.7។ សំណើរបស់ [redacted] សុំឲ្យ ក.ស.ច.ស ដាក់ប្រតិចារឹកពេញលេញ នៃការស្ដាប់ចម្លើយសាក្សីទាំងអស់ទៅក្នុងសំណុំរឿង, ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣,ឯកសារ D87/2/1.8 ។ សំណើរបស់ [redacted] សុំលក្ខណៈវិនិច្ឆ័យរបស់ ក.ស.ច.ស ពាក់ព័ន្ធ "អ្នកដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត", ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D87/2/1.10។ សំណើរបស់ [redacted] សុំឲ្យ ក.ស.ច.ស បង្គាប់ដល់ ក.ស.ព ឲ្យផ្តល់ដល់មេធាវីការពារក្ដី នូវលក្ខណៈវិនិច្ឆ័យរបស់ខ្លួនពាក់ព័ន្ធ "អ្នកដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត", ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D87/2/1.13។ ញត្តិរបស់ [redacted] ប្រឆាំងការអនុវត្តឧក្រិដ្ឋកម្មដែលមានចែងក្នុងមាត្រា ៣ថ្មី នៃ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (ឧក្រិដ្ឋកម្មជាតិ), ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D87/2/1.14។ ចុះខែ តុលា ឆ្នាំ ២០១៣, ឯកសារ D87/2/1.15។

[5] លិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធសារណារបស់សហមេធាវីដែលបានចាត់តាំង ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D87។ នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្ញើលិខិតជាបន្ទូមួយ ដោយបញ្ជាក់ថា គាត់ក៏បានទទួលញត្តិរបស់ [redacted] ជំទាស់ការអនុវត្ត សហឧក្រិដ្ឋកម្មរួម ប្រភេទទី...

ចំពោះការបដិសេធរបស់ ស.ច.ស.អ ក្នុងការពិចារណាទៅលើសំណើទាំងដប់បួន មុនពេលមានការសម្រេចលើបញ្ហាទំនាស់ផលប្រយោជន៍ ("បណ្តឹងឧទ្ធរណ៍លើការបដិសេធតាមការសន្មត")[6]។ សំណើទាំងដប់បីដែលពីដំបូងមិនត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង ត្រូវបានដាក់ចូលនៅពេលបន្ទាប់ដោយអង្គបុរេជំនុំជម្រះ ជាឧបសម្ព័ន្ធនៃបណ្តឹងឧទ្ធរណ៍លើការបដិសេធតាមការសន្មត។

4. ក្នុងអំឡុងរវាងថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ដល់ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៤ សហមេធាវី បានដាក់សំណើបួនបន្ថែមទៀត ទៅ ក.ស.ច.ស ហើយនៅពេលនោះមិនត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងនោះទេ ប៉ុន្តែបន្ទាប់មកត្រូវបានដាក់បញ្ចូលដោយអង្គបុរេជំនុំជម្រះ ជាឧបសម្ព័ន្ធនៃបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះ[7]។

5. នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញ សហមេធាវី មិនអាចធ្វើជាអ្នកតំណាងម្ចាស់បណ្តឹងឧទ្ធរណ៍បានទេ ដោយផ្អែកលើមូលដ្ឋាននៃទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន កើតចេញពីការធ្វើជាអ្នកតំណាងក្នុងពេលកន្លងមកឲ្យ អៀង សារី ក្នុងសំណុំរឿង ០០២ ហើយបានបដិសេធការតែងតាំងសហមេធាវី និងបង្គាប់ដល់អង្គភាពគាំពារការការពារក្តី ឲ្យធ្វើការតែងតាំងមេធាវីថ្មី សម្រាប់ម្ចាស់បណ្តឹងឧទ្ធរណ៍ ("សេចក្តីសម្រេចលើ

---

ហើយសំណើមួយផ្សេងទៀត ត្រូវសហចៅក្រមស៊ើបអង្កេតដកចេញពីបញ្ជីដែលមានរៀបរាប់នៅក្នុងលិខិតទីមួយរបស់គាត់។ សូមមើលលិខិតរបស់ ស.ច.ស.អ ផ្ញើរជូនសហមេធាវី សេចក្តីកែតម្រូវ និងសេចក្តីបន្ថែមលើលិខិត ក្រោមចំណងជើងថា "បញ្ជីសារណាដែលបានដាក់ដោយសហមេធាវីដែលបានចាត់តាំង ក្នុងសំណុំរឿង ០០៣" ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣, ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៣, ឯកសារ D87/1។

[6] បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសារណារបស់ [redacted] ចំនួន ដប់បួនច្បាប់ ដែលបានដាក់ទៅ ក.ស.ច.ស, ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣, ឯកសារ D87/2/1។

[7] ការជូនដំណឹងរបស់ [redacted] ដែលថាគាត់មានបំណងប្រើប្រាស់សិទ្ធិនៅស្ងៀមមិននិយាយស្តីរបស់គាត់ ហើយរាល់ការទំនាក់ទំនងនានាជាមួយគាត់ ត្រូវធ្វើឡើងតាមរយៈសហមេធាវីរបស់គាត់, ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣, ឯកសារ D87/2/1.2។ សារណារបស់ [redacted] ប្រឆាំងការប្រើប្រាស់ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដោយសារតែការហួសអាជ្ញាយុកាលដែលនៅជាធរមាន ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ D87/2/1.3។ សំណើរបស់ [redacted] សុំការស្រាយបំភ្លឺពាក់ព័ន្ធនឹងស្ថានភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ D87/2/1.4។ សំណើរបស់ [redacted] សុំឲ្យសហចៅក្រមស៊ើបអង្កេតពន្យល់អំពីការយល់ឃើញនូវអ្វីដែលនឹងកើតឡើង ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេត និងចៅក្រមអង្គបុរេជំនុំជម្រះមានការខ្វែងគំនិតគ្នាចំពោះថាតើត្រូវបិទកិច្ចស៊ើបសួរ ឬក៏ត្រូវចាប់ខ្លួន ចោទប្រកាន់ ឬបញ្ជូនលោក [redacted] ទៅជំនុំជម្រះ ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D87/2/1.5។

ទំនាស់")[8]។ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៤ សហមេធាវី បានដាក់ការជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ប្រឆាំងសេចក្តីសម្រេចលើទំនាស់ ក្នុងនាមម្ចាស់បណ្តឹងឧទ្ធរណ៍ ហើយនៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ម្ចាស់បណ្តឹងឧទ្ធរណ៍បានបញ្ជាក់ពីចេតនារបស់គាត់ក្នុងការប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចលើទំនាស់ ("បណ្តឹងឧទ្ធរណ៍លើទំនាស់")[9]។ សារណាបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤[10]។

6. នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្គាប់ដល់អង្គភាពគាំពារការការពារក្តីឱ្យធ្វើការតែងតាំងមេធាវីបណ្តោះអាសន្ន សម្រាប់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋានដែលថា បញ្ហានីតិវិធីអាចកើតមានឡើងមុនពេលមានដំណោះស្រាយ លើបណ្តឹងឧទ្ធរណ៍លើទំនាស់ ដែលអាចតម្រូវឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវមានមេធាវីតំណាង និងដើម្បីជៀសផុតពីការពន្យាពេលដោយមិនសមហេតុផល ក្នុងកិច្ចស៊ើបអង្កេត ("ដីកាបង្គាប់ឱ្យតែងតាំងមេធាវីបណ្តោះអាសន្ន")[11]។ នៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៤ សហមេធាវីបានស្នើដល់អង្គបុរេជំនុំជម្រះឱ្យផ្អាកការអនុវត្តដីកាបង្គាប់នេះ[12]។

7. នៅថ្ងៃទី ០៣ ខែ កុម្ភៈ និងថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ សហមេធាវីបានដាក់សំណើបន្ថែមទៀតចំនួនពីរ ហើយសំណើទាំងនេះមិនត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងនៅពេលនោះទេ ប៉ុន្តែបន្ទាប់

---

[8] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបដិសេធការតែងតាំងសហមេធាវី ដែលត្រូវបានចាត់តាំងដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D56/18។

[9] សេចក្តីជូនដំណឹងអំពីប្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធការតែងតាំងសហមេធាវីការពារក្តី ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D56/19។ សេចក្តីជូនដំណឹងរបស់ [redacted] ស្តីពីចេតនាប្តឹងឧទ្ធរណ៍ប្រឆាំងនឹង*សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិឱ្យច្រានចោលការតែងតាំងសហមេធាវីរបស់* [redacted] *ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន* ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D56/19/13។

[10] បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត Harmon លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យច្រានចោលការតែងតាំងសហមេធាវីរបស់ [redacted] ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ D56/19/24។

[11] ដីកាសម្រេចចាត់តាំងមេធាវីបណ្តោះអាសន្នឱ្យជនសង្ស័យ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D56/21។

[12] សំណើជាប្រញាប់ និងបន្ទាន់ដែលបានកែប្រែ របស់សហមេធាវីលោក [redacted] សុំឱ្យផ្អាកការអនុវត្តដីកាសម្រេចជាសម្ងាត់របស់សហចៅក្រមស៊ើបអង្កេត Harmon ដែលបង្គាប់ឱ្យ អ.គ.ក ចាត់តាំងសហមេធាវីថ្មីដើម្បីការពារលោក [redacted] ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៤ ឯកសារ D56/19/4។

មកត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង ដោយអង្គបុរេជំនុំជម្រះ ជាឧបសម្ព័ន្ធនៃបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះ[13]។

8. នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ អង្គបុរេជំនុំជម្រះបានសម្រេចថា ខ្លួនមិនមានយុត្តាធិការ ក្នុងការព្យួរដីកាបង្គាប់ឱ្យតែងតាំងមេធាវីបណ្តោះអាសន្នទេ ព្រោះការអនុវត្តដីកានេះ នឹងមិនបង្កជាព្យសនកម្មដល់សិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចលើទំនាស់ឡើយ (“សេចក្តីសម្រេចលើសំណើសុំឱ្យផ្អាក ការអនុវត្តដីកាសម្រេច ឱ្យតែងតាំងមេធាវីបណ្តោះអាសន្ន”)[14]។

9. នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មត (“សេចក្តីសម្រេចលើការបដិសេធតាមការសន្មត”)[15] ដោយសម្រេចថា “ពុំមានបញ្ហាសិទ្ធិឡើយ ទាក់ទិនទៅនឹងសិទ្ធិ និងលទ្ធភាពក្នុងការធ្វើជាតំណាង [ឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍] ព្រោះបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់មុនពេលការតែងតាំងសហមេធាវីត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[16]។ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន ដោយសារតែបណ្តឹងឧទ្ធរណ៍នេះទាក់ទងទៅនឹងសំណើសុំចំនួន ១៣ ក្នុងចំណោមសំណើចំនួន ១៤។ ប៉ុន្តែអង្គបុរេជំនុំជម្រះពន្យារការសម្រេច ទៅលើបណ្តឹងឧទ្ធរណ៍ទាក់ទិននឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការសម្រេចលើសំណើសុំចូលពិនិត្យមើលសំណុំរឿង រហូតដល់ពេលបណ្តឹងឧទ្ធរណ៍លើទំនាស់ត្រូវបានសម្រេច[17]។

---

[13] ពាក្យសុំរបស់ [redacted] ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការសំណើសុំមោឃភាពកិច្ចស៊ើបអង្កេតទាំងអស់ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មចំនួនពីរដែលរងការចោទប្រកាន់ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D103/1.6។ ពាក្យសុំរបស់លោក [redacted] ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការសំណើសុំមោឃភាពកិច្ចស៊ើបអង្កេតទាំងអស់ដែលទាក់ទងនឹងការធ្វើទុក្ខបុកម្នេញខាងសាសនា ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D103/1.7។

[14] សេចក្តីសម្រេចលើសំណើសុំឱ្យផ្អាកការអនុវត្តដីកាសម្រេចឱ្យតែងតាំងមេធាវីបណ្តោះអាសន្នសម្រាប់លោក [redacted] ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ D56/19/14។

[15] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់សហចៅក្រមស៊ើបអង្កេតទៅលើសារណារបស់ [redacted] ចំនួនដប់បួនច្បាប់ដែលបានដាក់ទៅ [ការិយាល័យសហចៅក្រមស៊ើបអង្កេត] ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D87/2/2។

[16] ដូចខាងលើ កថាខណ្ឌ ៦។

[17] ដូចខាងលើ កថាខណ្ឌ ១៣។

10. នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់ការជូនដំណឹងដែលចុះហត្ថលេខាដោយម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលក្នុងការជូនដំណឹងនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍បានបញ្ជាក់ថាគាត់ចង់ឱ្យសហមេធាវីធ្វើជាអ្នកតំណាងរបស់គាត់ ហើយគាត់មានបំណងប្រើប្រាស់សិទ្ធិនៅស្ងៀមរបស់គាត់។ ការជូនដំណឹងនេះមិនត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងទេ នៅពេលនោះ ប៉ុន្តែត្រូវបានដាក់បញ្ចូលនៅពេលបន្ទាប់មក ដោយអង្គបុរេជំនុំជម្រះ ជាឧបសម្ព័ន្ធនៃបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ន[18]។

11. នៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីសម្រេចទទួលស្គាល់ការតែងតាំងបណ្តោះអាសន្ន សហមេធាវី កែត ឃី និង Alan YATVIN ជាមេធាវីបណ្តោះអាសន្នរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍[19]។

## ខ. បណ្តឹងឧទ្ធរណ៍

12. នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៤ សហមេធាវី បានដាក់បណ្តឹងឧទ្ធរណ៍ ដែលក្នុងនោះសហមេធាវីបានស្នើដល់អង្គបុរេជំនុំជម្រះឱ្យទទួលយកយុត្តាធិការ តាមវិធាន ២១ នៃវិធានផ្ទៃក្នុង បង្គាប់ដល់ការិយាល័យសហចៅក្រមស៊ើបអង្កេត ឱ្យដាក់សំណើទាំងអស់ចូលទៅក្នុងសំណុំរឿង និងចាត់ការលើសំណើទាំងអស់ដែលកំពុងរង់ចាំសម្រេច[20]។ សហមេធាវីបានលើកទឡ្ហីករណ៍ថា "ផ្នែកទាំងមូលនៃសិទ្ធិក្នុងការរៀបចំកិច្ចការពារក្តី គឺការធ្វើកំណត់ត្រា ដើម្បីរក្សាទុកនូវការភ័ន្តច្រឡំផ្លូវច្បាប់ អង្គហេតុ ឬការរំលោភបំពានធន្មានុសិទ្ធិ" ហើយជាលទ្ធផលកំណត់ត្រាបែបនេះនឹងមិនមាននោះឡើយ ប្រសិនបើសំណើសុំមិនត្រូវបានដាក់ទៅក្នុងសំណុំរឿងទេ[21]។ លើសពីនេះ សហមេធាវីបានលើកឡើងថា មាត្រា ៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង នៅក្នុងករណីដែលភាគីមួយដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ និងមានហេតុផលទៅចៅក្រមស៊ើបអង្កេតណាម្នាក់ "ចៅក្រម

[18] សេចក្តីជូនដំណឹងរបស់ [redacted] ស្តីពីជម្រើសមេធាវីការពារក្តីរបស់គាត់ ក្នុងពេលរង់ចាំសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ស្តីពីទំនាស់ផលប្រយោជន៍ និងសេចក្តីជូនដំណឹងស្តីពីការបញ្ជាក់បន្ថែមទៀតអំពីចេតនាអនុវត្តសិទ្ធិនៅស្ងៀម ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឯកសារ D103/1.8។

[19] ដីកាសម្រេចលើការទទួលស្គាល់មេធាវីតំណាងជនសង្ស័យ នៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ D56/21/8/1។

[20] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៧។

[21] ដូចខាងលើ កថាខណ្ឌ ២០។

ស៊ើបអង្កេតនោះ ត្រូវតែចេញដីកាសម្រេចដោយមានសំអាងហេតុក្នុងរយៈពេលមួយខែ គិតចាប់ពីពេលទទួលបានពាក្យសុំ ប្រសិនបើគាត់សម្រេចថា មិនយល់ព្រមតាមពាក្យសុំនោះ”[22]។

13. នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតប[23] ដោយលើកទឡ្ហីករណ៍ថា សហមេធាវីមិនមានឋានៈមុខងារដើម្បីការពារក្តីឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍ទេ ដោយសារតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងអង្គបុរេជំនុំជម្រះបានចេញ “ដីកាសម្រេច” រារាំងសហមេធាវី មិនឱ្យបន្តដឹកនាំការងារសំណុំរឿង លើបញ្ហាពាក់ព័ន្ធការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣[24]។ សហព្រះរាជអាជ្ញាអន្តរជាតិបានដកស្រង់អនុស្សរណៈមួយដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញកាលពីថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៤ ផ្ញើជូនមេធាវីបណ្តោះអាសន្នរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលក្នុងអនុស្សរណៈនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ថា “[សហមេធាវី] លែងមានសិទ្ធិការពារជនសង្ស័យ ចាប់តាំងពី[សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] បានចេញដីកាសម្រេចលើទំនាស់ផលប្រយោជន៍ នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៤ និងចាប់តាំងពីទទួលស្គាល់ [មេធាវីបណ្តោះអាសន្នរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍] ពេញលេញ”[25]។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានពឹងផ្អែកផងដែរទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ លើសំណើសុំឱ្យផ្អាកការអនុវត្តដីកាសម្រេចឱ្យតែងតាំងមេធាវីបណ្តោះអាសន្នសម្រាប់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលអង្គបុរេជំនុំជម្រះសម្រេចថា មេធាវីបណ្តោះអាសន្ននឹងតំណាង

---

[22] ដូចខាងលើ កថាខណ្ឌ ២៩។

[23] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសហមេធាវីចាត់តាំង៖ (១) “បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបន្តបដិសេធរបស់សហចៅក្រមស៊ើបអង្កេត Harmon មិនដាក់សំណើសុំការពិចារណាទាំងឡាយរបស់ [redacted] ទៅក្នុងសំណុំរឿង និងការបន្តបដិសេធមិនចាត់ការលើសំណើទាំងនេះ” និង (២) “សំណើប្រញាប់ និងបន្ទាន់របស់ [redacted] សុំការស្រាយបំភ្លឺស្តីពីឋានៈមុខងាររបស់សហមេធាវីការពារក្តីឱ្យលោក [redacted] ក្នុងពេលរង់ចាំសេចក្តីសម្រេចស្ថាពរអំពីទំនាស់ផលប្រយោជន៍” ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D103/2 (“ចម្លើយតប”)។

[24] ដូចខាងលើ កថាខណ្ឌ ១៥។

[25] អនុស្សរណៈស្តីពីតំណាងផ្លូវច្បាប់របស់ជនសង្ស័យ [redacted] នៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ A41 ទំព័រ ២ *ដែលត្រូវបានយោងនៅក្នុង*ចម្លើយតប ទំព័រ ២។

01009050



ម្ចាស់បណ្តឹងឧទ្ធរណ៍ សម្រាប់ការស៊ើបអង្កេតតាមផ្លូវតុលាការ រហូតដល់បណ្តឹងឧទ្ធរណ៍លើទំនាស់ត្រូវបានសម្រេច[26]។

14. នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ សហមេធាវី បានដាក់ការឆ្លើយតប[27] ដែលក្នុងនោះ ពួកគាត់បានលើកទឡ្ហីករណ៍ថា សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងដោយខុសឆ្គងថា ការសម្រេចរបស់អង្គបុរេជំនុំជម្រះជា "ដីកាសម្រេច" ដែលថាសហមេធាវីមិនមានតួនាទីក្នុងការដាក់បណ្តឹងឧទ្ធរណ៍នេះទេ។ ផ្ទុយទៅវិញ សហមេធាវីបានលើកឡើងថា អង្គបុរេជំនុំជម្រះយល់ឃើញថា ខ្លួនមិនមានយុត្តាធិការក្នុងការផ្អាកដីកាតែងតាំងមេធាវីបណ្តោះអាសន្ន ហើយតាមមតិយោបល់របស់ចៅក្រម បានធ្វើការពន្យល់ពីការយល់ឃើញរបស់ខ្លួនចំពោះដីកា ពីព្រោះដីកាសម្រេចនឹងមិនប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ ដែលអង្គជំនុំជម្រះបានទទួលទេ[28]។ ហេតុដូច្នេះ ការពន្យល់របស់អង្គបុរេជំនុំជម្រះទៅលើការអនុវត្តដីកា មិនអាចចាត់ទុកថាជាដីកាហាមឃាត់ សហមេធាវី មិនឲ្យធ្វើជាអ្នកតំណាងម្ចាស់បណ្តឹងឧទ្ធរណ៍ ទេ តែបែរជាពង្រឹងកាតព្វកិច្ចសីលធម៌របស់សហមេធាវី ក្នុងការដឹកនាំការងារសំណុំរឿង រហូតដល់ទីបញ្ចប់[29]។

## គ. ការវិវឌ្ឍបន្ថែមទៀត

15. នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៤ អង្គបុរេជំនុំជម្រះបានប្រកាសផ្នែកសម្រេចសេចក្តីរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍លើទំនាស់ ដោយច្រានចោលសេចក្តីសម្រេចលើទំនាស់ និងទទួលស្គាល់សហ

---

[26] សេចក្តីសម្រេចលើសំណើសុំឲ្យផ្អាកការអនុវត្តដីកាសម្រេចឲ្យតែងតាំងមេធាវីបណ្តោះអាសន្នសម្រាប់លោក [redacted] ឯកសារ D56/19/14 កថាខណ្ឌ ១៧ *ដែលត្រូវបានយោងនៅក្នុង*ចម្លើយតប កថាខណ្ឌ ១៥។

[27] ការឆ្លើយតបរបស់ [redacted] ទៅនឹងចម្លើយរួមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ តបទៅនឹងសហមេធាវីចាត់តាំង៖ (១) "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេត Harmon មិនដាក់សំណើសុំការពិចារណាទាំងឡាយរបស់ [redacted] ទៅក្នុងសំណុំរឿង និងការបដិសេធមិនចាត់ការលើសំណើទាំងនេះ" និង (២) "សំណើប្រញាប់ និងបន្ទាន់សុំការស្រាយបំភ្លឺស្តីពីឋានៈមុខងាររបស់សហមេធាវីការពារក្តីឲ្យលោក [redacted] ក្នុងការរង់ចាំសេចក្តីសម្រេចស្តាពរអំពីទំនាស់ផលប្រយោជន៍" ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D103/3 ("ការឆ្លើយតប")។

[28] ដូចខាងលើ កថាខណ្ឌ ១-២។

[29] ដូចខាងលើ កថាខណ្ឌ ៣។

មេធាវីជាអ្នកតំណាងតាមផ្លូវច្បាប់របស់ម្ចាស់បណ្ដឹងឧទ្ធរណ៍។ សំអាងហេតុចំពោះសេចក្ដីសម្រេចនេះ ត្រូវបានចេញនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤[30]។

16. នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៤ សហមេធាវីបានដាក់សំណើទៅ ក.ស.ច.ស សុំឱ្យដាក់ "សំណើសុំការពិចារណាទាំងអស់" ទៅក្នុងសំណុំរឿង ("សំណើសុំដាក់ចូលទៅក្នុងសំណុំរឿង")[31]។

17. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានជូនដំណឹងដល់ម្ចាស់បណ្ដឹងឧទ្ធរណ៍ និងសហព្រះរាជអាជ្ញា ថា គាត់កំពុងធ្វើការពិចារណាឡើងវិញ លើសំណើសុំចូលពិនិត្យមើលសំណុំរឿង ហើយបានអញ្ជើញឱ្យដាក់សារណាបន្ថែម ដោយសារតែការត្រួតពិនិត្យមើលសំណើនេះ រួមបញ្ចូលទាំងការពិចារណាឡើងវិញនូវសេចក្ដីសម្រេចលើកមុន ដែលចេញដោយអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង[32]។

18. នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានច្រានចោលសំណើរបស់សហមេធាវី សុំដាក់ចូលទៅក្នុងសំណុំរឿង ដោយសម្រេចថា "វិសាលភាពនៃសិទ្ធិរបស់អ្នកដាក់សំណើក្នុងការដាក់សារណានានា គឺអាស្រ័យទៅលើ ដូចជា ឋានៈរបស់គាត់ជាជនសង្ស័យ ឬជាជនត្រូវចោទ នៅក្នុងកិច្ចស៊ើបសួររបស់តុលាការ" ដែលបច្ចុប្បន្ននេះកំពុងតែពិចារណា នៅក្នុងបរិបទនៃការត្រួតពិនិត្យសំណើទាក់ទងនឹងការសុំចូលពិនិត្យមើលសំណុំរឿង[33]។ អាស្រ័យហេតុ

---

[30] សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ច្រានចោលការតែងតាំង អាង ឧត្តម និង Michael KARNAVAS ជាសហមេធាវី ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D56/19/36 (ទម្រង់ខ្លី) និងសាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបដិសេធការតែងតាំងលោក អាង ឧត្តម និងលោក Michael KARNAVAS មិនឱ្យធ្វើជាសហមេធាវីរបស់គាត់ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D56/19/38 (សំអាងហេតុទាំងស្រុង) ។

[31] សំណើរបស់ [redacted] សុំឱ្យដាក់សំណើសុំការពិចារណាទាំងអស់ទៅក្នុងសំណុំរឿង ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D108។

[32] ការជូនដំណឹងទាក់ទងនឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត (D82) និងសុំឯកសារទាំងមូលនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងសម្ភារៈគាំទ្រ (D82/2) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D82/3។

[33] ដីកាសម្រេចលើសំណើរបស់ [redacted] សុំឱ្យដាក់សំណើសុំការពិចារណាទាំងអស់ទៅក្នុងសំណុំរឿង ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D108/1 កថាខណ្ឌ ៣។

នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចថា "ការដាក់សារណារបស់ជនសង្ស័យចូលទៅក្នុងផ្នែកខ្លឹមសារនៃសំណុំរឿង និងការឆ្លើយតបទាំងនោះ គ្រាន់តែអាចត្រូវបានពិចារណាតាមករណីនីមួយៗតែប៉ុណ្ណោះ នៅពេលដែលឋានៈរបស់គាត់ត្រូវបានបញ្ជាក់"[34]។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបែរជាបង្គាប់ដល់ក្រឡាបញ្ជីរបស់ ក.ស.ច.ស ឱ្យ"ដាក់សារណាចូលក្នុងសំណុំរឿង" "ផ្នែកឯកសាររដ្ឋបាល" ខណៈដែល"រង់ចាំការសម្រេចចុងក្រោយលើឋានៈរបស់ជនសង្ស័យ" ដើម្បីរក្សាទុកជាកំណត់ត្រា[35]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសង្កត់ធ្ងន់ថា សារណាទាំងអស់ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះ "បានដាក់រួចហើយជាឧបសម្ព័ន្ធ" ភ្ជាប់ជាមួយនឹងបណ្តឹងឧទ្ធរណ៍មុន និងបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ន ប្រឆាំងនឹងការបដិសេធតាមការសន្មត[36]។

## II. ការពិចារណា

19. អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា សេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍លើទំនាស់ ដែលសហមេធាវីត្រូវបានទទួលស្គាល់ថាជាអ្នកតំណាងផ្លូវច្បាប់ សម្រាប់ម្ចាស់បណ្តឹងឧទ្ធរណ៍ បានបដិសេធសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការបដិសេធជាលើកដំបូង ក្នុងការដាក់សំណើទាំងអស់ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ន ទៅក្នុងសំណុំរឿង។ បន្ទាប់ពីមានការចេញសេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍លើទំនាស់ សហមេធាវីបានស្នើដល់ ក.ស.ច.ស ឱ្យដាក់ "សំណើសុំទាំងអស់របស់មេធាវីការពារក្តី" ចូលទៅក្នុងសំណុំរឿង។ សំណើនេះ ធ្វើឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ធ្វើការពិនិត្យឡើងវិញនូវជំហររបស់គាត់ អំពីជោគវាសនារបស់សារណាដែលពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ន និងចេញសេចក្តីសម្រេចថ្មីចំពោះបញ្ហានេះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិទទួលស្គាល់ថា សំណើសុំគឺជាផ្នែកនៃសំណុំរឿង នៅពេលឥឡូវនេះ ព្រោះសំណើទាំងនេះត្រូវបានដាក់ចូលក្នុងសំណុំរឿង ជាឧបសម្ព័ន្ធនៃបណ្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដូច្នេះគឺបានដោះស្រាយបញ្ហានៃការបង្កើត "កំណត់ត្រា" ដែលសហមេធាវីបានលើកឡើងរួចហើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានប្រកាសបន្ថែមទៀតថា គាត់កំពុងធ្វើការពិចារណាទៅលើឋានៈរបស់សហមេធាវី ក្នុងការដាក់សារណាពាក់ព័ន្ធ ដែលនឹង

[34] ដូចខាងលើ កថាខណ្ឌ ៥។

[35] ដូចខាងលើ កថាខណ្ឌ ៧។

[36] ដូចខាងលើ កថាខណ្ឌ ៥។

ត្រូវទទួលបានការពិចារណា តាមករណីនីមួយៗ នៅពេលដែលឋានៈផ្លូវច្បាប់របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានសម្រេច។ សេចក្តីសម្រេចដែលបណ្តឹងឧទ្ធរណ៍ព្យាយាមធ្វើការជំទាស់ ឧទាហរណ៍ដូចជា លិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ និងការបដិសេធបន្តបន្ទាប់ លើការដាក់សំណើនីមួយៗ ចំនួនម្ភៃ ទៅក្នុងសំណុំរឿង ដោយផ្អែកលើមូលដ្ឋានគ្មានការទទួលស្គាល់សហមេធាវី គឺមិនមានអានុភាពតទៅទៀតឡើយ។ ក្នុងកាលៈទេសៈនេះ បណ្តឹងឧទ្ធរណ៍ ដូចដែលបានតាក់តែងឡើងនោះ គឺមិនមានអានុភាពទៀតទេ។

### III. ផ្នែកសម្រេចសេចក្តី

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

បដិសេធចោលបណ្តឹងឧទ្ធរណ៍នេះ ដោយមិនមានព្យសនកម្មអ្វី ចំពោះសិទ្ធិនានាឡើយ។

អនុលោមតាមវិធាន៧៧ (១៣) សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៤**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

ប្រាក់ គឹមសាន Rowan DOWNING **ន៍យ ថុល** **Chang-ho CHUNG** **ហួត វុទ្ធី**

*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបន្តបដិសេធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនដាក់សំណើសុំការពិចារណាទាំងឡាយរបស់ [redacted] ទៅក្នុងសំណុំរឿង និងការបន្តបដិសេធមិនចាត់ការលើសំណើទាំងនេះ*